សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស (តមកពីលេខមុន)

www.hoksavann.org

ថ្ងៃទី២ វិច្ឆិកា ២០១២



១៥- សំនួរ ៖ អ្នកណាខ្លះអាចធ្វើការដើម្បីជាប្រយោជន៍ដល់សិទ្ធិមនុស្ស ?

ចម្លើយ ៖ សិទ្ធិមនុស្សជាកិច្ចការរបស់យើងគ្រប់ៗគ្នា ។ ទាំងអស់គ្នាចាំបាច់ត្រូវតែធ្វើការដើម្បីសិទ្ធិមនុស្ស ។ អ្នកណាក៏អាចធ្វើការដើម្បីសិទ្ធិមនុស្សបានដែរ ។ ឧទាហរណ៍ ព្រះសង្ឃអាចធ្វើការខាងវិស័យសិទ្ធិមនុស្សបានយ៉ាងងាយ ព្រោះអីសិទ្ធិមនុស្សជាផ្នែកមួយនៅក្នុងឱវាទរបស់ព្រះពុទ្ធជាម្ចាស់ ហើយព្រះសង្ឃជាតំណាងនៃជំនឿ និងសេចក្តីគោរពរបស់ខ្មែរ ។ ព្រះសង្ឃមិនគ្រាន់តែអាចប្រើសិទ្ធិនិងសេរីភាពក្នុងការកាន់សាសនា និងជំនឿប៉ុណ្ណោះទេ ព្រះសង្ឃអាចការពារសិទ្ធិសិទ្ធិប្រជាពលរដ្ឋនៅក្នុងភូមិស្រុកបានទៀតផង ។ ព្រះសង្ឃតែងតែដឹងថា ពេលណារបបនយោបាយណាមួយចង់ប្រព្រឹត្តរំលោភសិទ្ធិមនុស្ស របបនោះមុខជានឹងផ្តើមឆាឆៅព្រះសង្ឃ និងព្រះពុទ្ធសាសនាមុនគេ ។

មាតាបិតាក៏អាចធ្វើកិច្ចការក្នុងរឿងការពារសិទ្ធិមនុស្សបានដែរ តាមពិតមាតាបិតាចាំបាច់ត្រូវតែធ្វើកិច្ចការនេះ ដើម្បីការពារសិទ្ធិបុត្រធិតាខ្លួន ។ ហើយបុត្រធិតាដែលធំៗក៏អាចធ្វើការនេះ ដើម្បីការពារសិទ្ធិមាតាបិតាខ្លួនផង សិទ្ធិប្អូនៗខ្លួនផង ។ គ្រួសារគឺជាកម្លាំងជួរមុខក្នុងការការពារសិទ្ធិមនុស្ស ។ ព្រោះហេតុនេះបានជា កាលណាមានរបបណាមួយចង់ប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្ស គេត្រូវគិតគូរពីរឿងបំបែកបំបាក់គ្រួសារជាមុនសិន ។

ស្ត្រីចាំបាច់ត្រូវតែខំបំពេញកិច្ចការសិទ្ធិមនុស្ស ដើម្បីការពារសិទ្ធិរបស់នារីភេទផង និងលើកស្ទួយសិទ្ធិមនុស្សជាទូទៅផង។ សិស្សឬនិស្សិតអាចបំពេញភារកិច្ចខាងវិស័យសិទ្ធិមនុស្ស ដោយខំសិក្សាឲ្យបានចេះដឹងគ្រប់គ្រាន់ ដើម្បីបង្រៀនសិស្សឯទៀត ។ សិទ្ធិមានសារៈសំខាន់ណាស់ចំពោះអ្នកដែលនៅវ័យក្មេង ព្រោះអីអនាគតរបស់ប្រទេសជាតិនីមួយៗស្ថិតនៅលើក្មេងៗ ។ គ្រូបង្រៀនក៏អាចជួយក្នុងកិច្ចការសិទ្ធិមនុស្សបានដែរ ព្រោះគ្រូអាចបង្រៀនសិស្សក្នុងថ្នាក់របស់ខ្លួនអំពីសិទ្ធិមនុស្ស ឬបើពុំនោះសោតទេ គ្រូអាចបង្រៀនអំពីវិជ្ជានេះមុនឬក្រោយពេលម៉ោងបង្រៀនធម្មតាក៏បានដែរ ។ មេធាវី (អ្នកច្បាប់) អាចជួយជ្រោមជ្រែងក្នុងរឿងសិទ្ធិមនុស្សបាន តាមការខិតខំកែទម្រង់ច្បាប់ឲ្យកាន់តែប្រពៃឡើង ហើយនិងតាមការជួយការពារសិទ្ធិពលរដ្ឋនៅតុលាការកាត់ក្តី ឬនៅក្នុងប្រព័ន្ធច្បាប់ ។ កសិករអាចរួមចំណែកក្នុងការទ្រទ្រង់សិទ្ធិមនុស្ស ដោយប្រើសិទ្ធិខ្លួនក្នុងការទាមទារឲ្យមានប្រាក់កំរៃសមរម្យតាមទំហំការ ហើយនិងទទូចទាមទារឲ្យមានភាពស្មើគ្នា ក្នុងការចែកចាយជូនប្រជាពលរដ្ឋនូវភោគផលនៃអភិវឌ្ឍន៍សេដ្ឋកិច្ច និងជំនួយបរទេស ។ អភិបាលភូមិអាចជួយការពារសិទ្ធិមនុស្ស ដោយតវ៉ាទាមទារកុំឲ្យពួកអ្នកទីក្រុងចេះតែស្រូបយកសម្បត្តិជាតិតែឯងពេក ។ ម៉្យាងទៀត អភិបាលភូមិមានភារកិច្ចរាយការណ៍ជូនអង្គការសហប្រជាជាតិ ប្រសិនបើមានទាហានឬកម្មាភិបាលនយោបាយណាមួយចូលមកគំរាមកំហែងប្រជាពលរដ្ឋក្នុងភូមិ ។ តម្រួតហើយនិងភ្នាក់ងារមន្ទីរឃុំឃាំង ក៏អាចរួមចំណែកក្នុងវិស័យនេះបានដែរ ដោយខិតខំប្រតិបត្តិតាមក្បួនវិន័យមិនឲ្យល្មៀង ព្រមទាំងខំអប់រំតម្រួតឬឆ្មាំឯទៀតៗឲ្យចេះគោរពសិទ្ធិរបស់អ្នកជាប់ឃុំឃាំង ។ អ្នកជាប់ឆ្នោតជាសមាជិករដ្ឋាភិបាល ហើយនិងបេក្ខជនខាងផ្នែកនយោបាយនានា អាចជួយជ្រោមជ្រែងសិទ្ធិមនុស្សដោយគោរពច្បាប់រដ្ឋឲ្យជិតដល់ ដោយខំបង្ហាញថា ខ្លួនខិតខំទ្រទ្រង់ និងគោរពសិទ្ធិមនុស្ស ដោយមិនលើកដម្កើង មិនឲ្យរង្វាន់ ឬមិនការពារអ្នកកាន់រដ្ឋអំណាចឯទៀតៗដែលមិនគោរព ឬដែលរំលោភសិទ្ធិមនុស្ស ។ ទាហានក៏អាចរួមចំណែកក្នុងការជួយទ្រទ្រង់សិទ្ធិមនុស្សដែរ ដោយចងចាំជានិច្ចថា អាវុធពុំមែនជាឧបករណ៍សំរាប់រំលោភសិទ្ធិទេ ហើយក្នុងឋានៈជាទាហានការពារជាតិ អ្នកមិនត្រូវធ្វើអ្វីតាមតែអំពើចិត្តប្រាសចាកពីគន្លងច្បាប់វិន័យឡើយ ។

សូមចាំជានិច្ចថា អ្នកណាក៏អាចរួមចំណែកក្នុងការលើកដម្កើងសិទ្ធិមនុស្សបានដែរ ។ អ្នកពុំចាំបាច់មានវិជ្ជាខ្ពង់ខ្ពស់ ឬសញ្ញាប័ត្រអ្វីឡើយ ។ សិទ្ធិជាកម្មសិទ្ធិរបស់មនុស្សរាល់រូប ទាំងអ្នកមានចំណេះ ទាំងអ្នកគ្មានវិជ្ជា ទាំងអ្នកមានទ្រព្យ ទាំងអ្នកក្រីក្រ ។

១៦- សំនួរ ៖ តើអង្គការសហប្រជាជាតិធ្វើអ្វីខ្លះក្នុងវិស័យសិទ្ធិមនុស្ស ?

ចម្លើយ ៖ ១/ ការងារផ្នែកសិទ្ធិមនុស្សសំខាន់បំផុតរបស់អង្គការសហប្រជាជាតិ គឺអញ្ជើញរដ្ឋាភិបាលទាំងឡាយឲ្យទៅរួមប្រជុំគ្នា ដើម្បីកំណត់ឲ្យច្បាស់លាស់ ថាអ្វីដែលហៅថាសិទ្ធិមនុស្ស ហើយអ្វីខ្លះដែលជាការរំលោភសិទ្ធិមនុស្ស ។ ២/ ចំពោះរដ្ឋាភិបាលទាំងឡាយណាដែលបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិផ្នែកសិទ្ធិមនុស្ស អ.ស.ប.នឹងកោះហៅ ឲ្យទៅរួមប្រជុំដើម្បីពិភាក្សាទៅលើសកម្មភាពនានា ដែលប្រទេសទាំងនេះបានធ្វើការអនុវត្តន៍តាមកិច្ចព្រមព្រៀងផ្នែកសិទ្ធិមនុស្សនោះ ។ ៣/ អ.ស.ប.ពិនិត្យសាឡើងវិញ នូវការខ្លះដែលចេះតែមានការរំលោភយ៉ាងខ្លាំងៗហើយផ្ទួនៗគ្នា ទៅលើច្បាប់សិទ្ធិដែលអន្តរជាតិគេទទួលស្គាល់និងការពារ ។ ភាគច្រើន ការសើរើពិនិត្យនេះប្រព្រឹត្តឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្សអ.ស.ប. ដែលជាក្រុមមួយ ដែលមានរដ្ឋជាសមាជិក ទៅរួមប្រជុំនៅទីក្រុងហ្សឺណែវនៃប្រទេសស្វីសនៅក្នុងខែកុម្ភៈ និងមីនារាល់ៗឆ្នាំ ។

(នៅមានត)